**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :២៥៤ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងទារកដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានិងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការគ្រប់គ្រងនិងលក្ខណវិនិច្ឆ័យនៃការបង្កើតទារកដ្ឋានសម្រាប់មើលថែទាំទារកនិងកុមារតូច ក្នុងគោលបំណងដើម្បីផ្តល់ឱកាសដល់ការលូតលាស់និងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងតម្រូវការក្នុងការអភិវឌ្ឍមូលធនមនុស្ស កាត់បន្ថយបន្ទុក និងផ្តល់ពេលវេលាដល់មាតាបិតាឬអ្នកអាណាព្យាបាលមានឱកាសធ្វើការងាររកប្រាក់ចំណូលនិងប្រកបការងារផ្សេងៗ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះទារកដ្ឋានសហគមន៍ ទារកដ្ឋានសហគ្រាស និងទារកដ្ឋានឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

| | |
|---|---|
| កុមារតូច | : សំដៅដល់កុមារអាយុចាប់ពីកកំណើតរហូតដល់អាយុក្រោម៦(ប្រាំមួយ)ឆ្នាំ។ |
| ទារក | : សំដៅដល់កុមារតូចដែលមានអាយុពី០(សូន្យ)ខែ ដល់១២(ដប់ពីរ)ខែ។ |
| ទារកដ្ឋាន | : សំដៅដល់ទីកន្លែងថែទាំនិងអភិវឌ្ឍទារកនិងកុមារតូចចាប់ពីអាយុ៣(បី)ខែ រហូតដល់៣៦(សាមសិបប្រាំមួយ)ខែ លើកលែងតែមានច្បាប់ចែងដោយឡែក។ |
| ទារកវប្បករ | : សំដៅដល់អ្នកថែទាំទារកនិងកុមារតូចនៅក្នុងទារកដ្ឋាន ប្រកបដោយវិជ្ជាជីវៈ និងស្របតាមគោលការណ៍បច្ចេកទេស ដើម្បីឱ្យមានសុខភាពល្អនិងការអភិវឌ្ឍ។ |
| បុគ្គលិកទារកដ្ឋាន | : សំដៅដល់អ្នកដែលបំពេញការងារនៅក្នុងទារកដ្ឋាន រួមមានអ្នកគ្រប់គ្រងទារកដ្ឋាន ទារកវប្បករ ចុងភៅ អ្នកអនាម័យ និងសន្តិសុខ។ |
| អភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ | : សំដៅដល់ការអភិវឌ្ឍផ្នែករាងកាយនិងសុខភាព សីលធម៌និងវប្បធម៌ សង្គមនិងអារម្មណ៍ ការយល់ដឹងនិងពិចារណា និងផ្នែកភាសា។ |
| ការរៀនសូត្រវ័យដំបូង | : សំដៅដល់ដំណាក់កាលសំខាន់សម្រាប់កុមារ ដែលជួយឱ្យកុមារអាចអភិវឌ្ឍជំនាញ និងចំណេះដឹងនៅក្នុងវិស័យនានា។ នៅក្នុងវ័យនេះ កុមារមានភាពអាចទទួលយក និងរំពឹកព័ត៌មានបានល្អ ហើយការរៀនតាមរយៈការលេងនិងសកម្មភាពផ្សេងៗអាចជួយឱ្យពួកគេមានការយល់ដឹងល្អ។ |



Kម 𝓌

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងអប់រំ យុវជន និងកីឡា មានសមត្ថកិច្ចគ្រប់គ្រងទារកដ្ឋានសហគមន៍និងទារកដ្ឋានឯកជន។ ដោយឡែក ទារកដ្ឋានសហគ្រាស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៣
## លក្ខណវិនិច្ឆ័យនៃការបង្កើតទារកដ្ឋាន

**មាត្រា៥ .-**

ទារកដ្ឋានមាន៣(បី)ប្រភេទគឺ៖

- ទារកដ្ឋានសហគមន៍
- ទារកដ្ឋានសហគ្រាស
- ទារកដ្ឋានឯកជន។

**មាត្រា៦ .-**

ទារកដ្ឋានមានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- ផ្តល់សេវាមើលថែទាំនិងអភិវឌ្ឍដល់ទារកនិងកុមារតូច ដោយឈរលើគោលការណ៍សមធម៌និងបរិយាបន្ន
- ផ្តល់ឱកាសសម្រាប់ការរៀនសូត្រវ័យដំបូងដល់ទារកនិងកុមារតូច
- ផ្តល់សេវាថែទាំទារកនិងកុមារតូចប្រកបដោយការឆ្លើយតប
- ផ្តល់សុវត្ថិភាពដល់ទារកនិងកុមារតូចក្នុងទារកដ្ឋាន
- ផ្តល់ការសង្គ្រោះបឋមដល់ទារកនិងកុមារតូច។

**មាត្រា៧ .-**

ការរៀបចំទារកដ្ឋាន ត្រូវអនុលោមតាមលក្ខណវិនិច្ឆ័យដែលជាស្តង់ដារអប្បបរមា ដូចខាងក្រោម៖

- ទីតាំងច្បាស់លាស់និងបន្ទប់ផ្សេងៗសម្រាប់បំពេញការងារនិងបំពេញតម្រូវការរបស់ទារកនិងកុមារតូច
- ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍទារកដ្ឋាន
- រចនាសម្ព័ន្ធគ្រប់គ្រងទារកដ្ឋាន
- គុណវុឌ្ឍិនិងលក្ខណសម្បត្តិបុគ្គលិកទារកដ្ឋាន
- គោលការណ៍ណែនាំអំពីការថែទាំ អប់រំ និងពិនិត្យសុខភាពទារកនិងកុមារតូច
- កម្មវិធីគាំពារនិងអភិវឌ្ឍទារកនិងកុមារតូច
- បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងទារកដ្ឋាន។

**មាត្រា៨ .-**

ទារកដ្ឋានត្រូវមានទីតាំងស្ថិតនៅក្នុងតំបន់ដែលមានបរិស្ថានល្អ ស្ងប់ស្ងាត់ សុវត្ថិភាព មានអនាម័យ មានខ្យល់ចេញចូល មានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ គ្មានសំឡេងរំខាន និងមានទឹកស្អាតសម្រាប់ប្រើប្រាស់។

ទារកដ្ឋានត្រូវមានអគារដែលបែងចែកជាបន្ទប់ផ្សេងៗ ត្រូវបំពាក់សម្ភារៈបរិក្ខារទារកដ្ឋាន និងត្រូវមានទីធ្លាសម្រាប់ទារកនិងកុមារតូចលេង។ ទារកដ្ឋានត្រូវមានបន្ទប់ការងាររដ្ឋបាល បន្ទប់បំបៅ បន្ទប់ទឹកនិងបង្គន់ បន្ទប់ចម្អិន



Kry 1860

ឬកម្ដៅអាហារនិងញ៉ាំអាហារ បន្ទប់សម្រាប់ទារកនិងកុមារតូចគេង បន្ទប់សម្រាប់ទារកនិងកុមារតូចលេង បន្ទប់ឬប្រអប់សង្គ្រោះបឋម។

ការកំណត់ទំហំអប្បបរមានិងការរៀបចំហេដ្ឋារចនាសម្ព័ន្ធបន្ទប់តាមលក្ខណៈបច្ចេកទេសនៃទារកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

**មាត្រា៩ .-**

ទារកដ្ឋានត្រូវមានផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍រយៈពេល៣ឆ្នាំ ដែលបញ្ជាក់អំពីចក្ខុវិស័យ បេសកកម្ម គោលបំណង គោលដៅ និងផែនការសកម្មភាព ដោយបង្ហាញអំពីសកម្មភាពនិងធនធានសម្រាប់គាំទ្រនិងអភិវឌ្ឍ។

**មាត្រា១០ .-**

ទារកដ្ឋានត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់។

រចនាសម្ព័ន្ធគ្រប់គ្រងទារកដ្ឋានសហគមន៍និងទារកដ្ឋានឯកជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

រចនាសម្ព័ន្ធគ្រប់គ្រងទារកដ្ឋានសហគ្រាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១១ .-**

បុគ្គលិកទារកដ្ឋានត្រូវមានគុណវុឌ្ឍិនិងលក្ខណសម្បត្តិសក្តិសម ដើម្បីបម្រើការងារនៅក្នុងទារកដ្ឋាន។

គុណវុឌ្ឍិនិងលក្ខណសម្បត្តិសក្តិសមរបស់បុគ្គលិកទារកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

ទារកដ្ឋានត្រូវមានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិកទារកដ្ឋាន។

**មាត្រា១២ .-**

ទារកដ្ឋានត្រូវមានបុគ្គលិកបំពេញការងារស្របតាមនិយាម។

និយាមនៃការប្រើបុគ្គលិកទារកដ្ឋាន តាមគោលការណ៍កំណត់គឺ បុគ្គលិកទារកដ្ឋានយ៉ាងតិច៤(បួន)នាក់ មើលថែទាំទារកនិងកុមារតូច២៥(ម្ភៃប្រាំ)នាក់។

និយាមលម្អិតនៃការប្រើបុគ្គលិកទារកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៣ .-**

ទារកដ្ឋានត្រូវមានគោលការណ៍ណែនាំអំពីការថែទាំ អប់រំ និងពិនិត្យសុខភាពទារកនិងកុមារតូច ដែលឆ្លុះបញ្ចាំងអំពីការលើកកម្ពស់សុខុមាលភាព អាហារូបត្ថម្ភ ឱកាស និងការអភិវឌ្ឍសម្រាប់ការរៀនសូត្រតាំងពីវ័យដំបូង ការថែទាំប្រកបដោយការឆ្លើយតបនិងសុវត្ថិភាព។

**មាត្រា១៤ .-**

ទារកដ្ឋានត្រូវសហការជាមួយមាតាបិតាឬអ្នកអាណាព្យាបាល នាំទារកនិងកុមារតូចទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ឬទីតាំងកំណត់ណាមួយ ដើម្បីទទួលថ្នាំបង្ការនិងអន្តរាគមន៍ផ្សេងៗ ស្របតាមការកំណត់ក្នុងបណ្ណសុខភាពកុមារ ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល។

ក្នុងករណីទារកនិងកុមារតូចមានបញ្ហាសុខភាពឬគ្រោះថ្នាក់ដោយចៃដន្យណាមួយ បុគ្គលិកទារកដ្ឋានត្រូវផ្តល់ព័ត៌មានឱ្យបានរហ័សដល់មាតាបិតាឬអ្នកអាណាព្យាបាលទារកនិងកុមារតូច និងនាំទារកនិងកុមារតូចទៅមណ្ឌលសុខភាព ឬទៅរកសេវាពិនិត្យនិងព្យាបាលនៅមន្ទីរពេទ្យជំនាញដែលនៅជិតបំផុត។

**មាត្រា១៥ .-**

ទារកដ្ឋានត្រូវមានកម្មវិធីគាំពារនិងអភិវឌ្ឍទារកនិងកុមារតូចសម្រាប់នាំទារកនិងកុមារតូចលេងឬធ្វើសកម្មភាពនានាដើម្បីគាំទ្រការអភិវឌ្ឍគ្រប់ជ្រុងជ្រោយលើៈ

- ផ្នែករាងកាយនិងសុខភាព
- ផ្នែកវប្បធម៌និងសីលធម៌
- ផ្នែកសង្គមនិងអារម្មណ៍
- ផ្នែកការពិចារណានិងការយល់ដឹង
- ផ្នែកភាសា។

កម្មវិធីគាំពារនិងអភិវឌ្ឍទារកនិងកុមារតូច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៦ .-**

ទារកដ្ឋានត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងនិងថែរក្សាព័ត៌មានផ្ទាល់ខ្លួនជាក់លាក់និងត្រូវរក្សាឯកជនភាពរបស់ទារកនិងកុមារតូច។

នីតិវិធីនៃការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនជាក់លាក់របស់ទារកនិងកុមារតូច និងការផ្តល់ព័ត៌មានតាមការស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៧ .-**

ទារកដ្ឋានត្រូវមានបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងទារកដ្ឋាន ស្របតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៤
## ការបង្កើតទារកដ្ឋាន
### ផ្នែកទី១
### ការបង្កើតទារកដ្ឋានសហគមន៍

**មាត្រា១៨ .-**

ទារកដ្ឋានសហគមន៍ ត្រូវបង្កើតឡើងដោយដីការបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ តាមសំណើរបស់មេឃុំឬចៅសង្កាត់ ដើម្បីផ្តល់ការថែទាំទារកនិងកុមារតូចនៅតាមសហគមន៍។

**មាត្រា១៩ .-**

បែបបទនិងនីតិវិធីនៃការបង្កើតទារកដ្ឋានសហគមន៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## ការបង្កើតទារកដ្ឋានសហគ្រាស

**មាត្រា២០ .-**

ទារកដ្ឋានសហគ្រាស ត្រូវបង្កើតឡើងដោយនិយោជក ដើម្បីផ្តល់សេវាថែទាំទារកនិងកុមារតូច ដែលជាកូនរបស់កម្មករ និយោជិត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣
## ការបង្កើតទារកដ្ឋានឯកជន

**មាត្រា២១ .-**

ទារកដ្ឋានឯកជន ត្រូវបង្កើតឡើងដោយរូបវន្តបុគ្គលឬនីតិបុគ្គលឯកជន ដើម្បីផ្តល់សេវាថែទាំទារកនិងកុមារតូច។

ទារកដ្ឋានឯកជនដែលបង្កើតឡើងដោយរូបវន្តបុគ្គលឬនីតិបុគ្គលឯកជន ជាកម្មវត្ថុនៃការទទួលស្គាល់។

រូបវន្តបុគ្គលឬនីតិបុគ្គលឯកជន ដែលមានបំណងបង្កើតទារកដ្ឋានឯកជន ត្រូវស្នើសុំការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ផ្តល់ការទទួលស្គាល់ទារកដ្ឋានឯកជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៥
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា២២ .-**

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីជួយផ្នែកបច្ចេកទេសដល់ទារកដ្ឋានសហគមន៍។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទារកដ្ឋានសហគ្រាស ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតក្រុមការងារអន្តរក្រសួង សម្រាប់ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីផ្តល់ការកែលម្អផ្នែកបច្ចេកទេសដល់ទារកដ្ឋានឯកជន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២៣ .-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ក្នុងរយៈពេលយ៉ាងយូរ៤(បួន)ឆ្នាំ ទារកដ្ឋានដែលកំពុងដំណើរការ ត្រូវអភិវឌ្ឍឱ្យស្របតាមស្តង់ដាអប្បបរមាដូចមានចែងនៅក្នុងអនុក្រឹត្យនេះ។



ᵏᴺ ᴹ

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១០រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហេង សួរ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ